THE SCHOOL DISTRICT OF PHILADELPHIA

# កម្មវិធីបន្ថែមថ្ងៃសិក្សា (ESY) សម្រាប់សិស្សពិការ

**តើអ្វីទៅជាកម្មវិធីបន្ថែមថ្ងៃសិក្សា?** កម្មវិធីបន្ថែមថ្ងៃសិក្សា (ESY) ជាកម្មវិធីអប់រំពិសេសដែលឥតគិតថ្លៃ ផ្តល់ឲ្យសិស្សពិការ លើសពី១៨០ថ្ងៃ នៃឆ្នាំសិក្សា។ គោលបំណងសំខាន់របស់កម្មវិធីបន្ថែមថ្ងៃសិក្សានេះ គឺដើម្បីរក្សាការរីកចម្រើនរបស់សិស្ស ចំពោះ ផែនការ និង គោលបំណង សំខាន់បំផុត នៅក្នុងកំឡុងពេលនៃឆ្នាំសិក្សាធម្មតា។ កម្មវិធីបន្ថែមថ្ងៃសិក្សា គឺយោងទៅលើសេចក្តីត្រូវការរបស់សិស្សម្នាក់ៗ ហើយតាមធម្មតាមិនរួមបញ្ចូល ផែនការ និង គោលបំណង គ្រប់បែបយ៉ាងនៅក្នុង IEP របស់សិស្សនោះទេ។

**តើ សិទ្ធិ និងការបម្រើ នៃកម្មវិធីបន្ថែមថ្ងៃសិក្សា ត្រូវគេសម្រេចដោយរបៀបណា?** សិទ្ធិរបស់សិស្សសម្រាប់កម្មវិធីបន្ថែមថ្ងៃសិក្សា និងសេចក្តីត្រូវការសម្រាប់ការបម្រើរបស់កម្មវិធីបន្ថែមថ្ងៃសិក្សា ត្រូវពិភាក្សានៅក្នុងអង្គប្រជុំរបស់ក្រុម IEP របស់សិស្ស។ ចំនួន ប្រភេទ និង រយៈពេល នៃការបម្រើដែលត្រូវផ្តល់ឲ្យក្នុងកម្មវិធីបន្ថែមថ្ងៃសិក្សា គឺយោងទៅលើសេចក្តីត្រូវការរបស់សិស្សម្នាក់ៗ ហើយសម្រេចដោយក្រុម IEP ដោយយោងទៅលើទិន្នន័យដែលគេប្រមូលបាន អំពី ការប៉ិនប្រសប់ និងអាកប្បកិរិយា របស់សិស្ស។ កម្មវិធីបន្ថែមថ្ងៃសិក្សា មិនមែនរួមបញ្ចូលត្រឹមតែការអប់រំពិសេសនោះទេ ហើយអាចមានរួមទាំងការបម្រើដែលជាប់ទាក់ទងផ្សេងៗទៀត ដូចជា ការបង្រៀនឲ្យចេះធ្វើកិច្ចការ ការហាត់ឲ្យរាងកាយរឹងមាំ និងការរៀននិយាយ។

**តើ កម្មវិធីបន្ថែមថ្ងៃសិក្សា ធ្វើឡើងនៅពេលណា និងនៅទីណា?** កម្មវិធីបន្ថែមថ្ងៃសិក្សា ជាទូទៅផ្តល់ឲ្យនៅក្នុងអាគារសាលារបស់ក្រសួង នៅថ្ងៃ អង្គារ ពុធ និងថ្ងៃ ព្រហស្បតិ៍ ពីម៉ោង ៩:០០ ព្រឹក ដល់ ១:០០ រសៀល រយៈពេលប្រាំមួយសប្តាហ៍ នៅរដូវក្តៅ។ ទោះជាដូច្នេះក៏ដោយ ក៏គ្មានការកំណត់ ចំនួន ប្រភេទ ឬ រយៈពេល នៃកម្មវិធីបន្ថែមថ្ងៃសិក្សា ជាក់លាក់នោះទេ។ សិស្សម្នាក់ៗមានសិទ្ធិទទួលការបម្រើដែលចាំបាច់ដើម្បីធ្វើយ៉ាងណាឲ្យពួកគេទទួលការអប់រំទៅតាមសេចក្តីត្រូវការរបស់ពួកគេ។ លោកអ្នកគប្បីពិភាក្សានៅពេលជួបប្រជុំជាមួយក្រុម IEP ម្តងៗ ថាតើសិស្សត្រូវការការបម្រើ តិចជាងនេះ ច្រើនជាងនេះ ឬ ក៏ការបម្រើអ្វីផ្សេងទៀត។

**តើលោកអ្នកត្រូវធ្វើដូចម្តេច បើសិនជាលោកអ្នកមានសំណួរដែលទាក់ទងនឹងកម្មវិធីបន្ថែមថ្ងៃសិក្សា ឬចង់ស្នើសុំជួបប្រជុំ IEP ដើម្បីពិភាក្សាអំពី កម្មវិធីបន្ថែមថ្ងៃសិក្សា?** បើសិនជានៅពេលណាមួយ លោកអ្នកមានសំណួរ ឬចង់ពិភាក្សាបន្ថែមទៀតអំពីកម្មវិធីបន្ថែមថ្ងៃសិក្សា របស់សិស្ស លោកអ្នកអាចស្នើសុំការប្រជុំ IEP។ ដើម្បីស្នើសុំការប្រជុំ IEP ដើម្បីពិភាក្សាអំពីកម្មវិធីបន្ថែមថ្ងៃសិក្សារបស់សិស្ស សូមធ្វើតាមវិធីណាមួយដូចខាងក្រោមនេះ៖

> **ជម្រើសទី១៖** ទូរស័ព្ទ ឬ អ៊ីមែល ទៅគ្រូបង្រៀនកម្មវិធីអប់រំពិសេស នៅសាលារបស់សិស្ស
> និង/ឬ
> **ជម្រើសទី២៖** ទូរស័ព្ទ ឬ អ៊ីមែល ទៅអ្នកធ្វើទំនាក់ទំនងផ្នែកកម្មវិធីអប់រំពិសេស នៅសាលារបស់សិស្ស។